តើកូនរបស់អ្នកនឹងមានអាយុ 5 ឆ្នាំ នៅត្រឹមថ្ងៃទី 31 ខែសីហា មែនឬទេ?

ប្រសិនបើមែន **ឥឡូវនេះដល់ពេល** ចុះឈ្មោះចូលមត្តេយ្យសាលាហើយ!

**ទទួលជំនួយ** ក្នុងការចុះឈ្មោះ។ សូមទៅកាន់សាលាក្នុងតំបន់ ឬការិយាល័យមណ្ឌល។

# ការចុះឈ្មោះចូលមត្តេយ្យសាលាចាប់ផ្តើមពីថ្ងៃទី 19 មករា 2016៖ ហេតុអ្វីវាសំខាន់? ចំណុចដែលគួរពិភាក្សា

## អត្ថប្រយោជន៍នៃការចុះឈ្មោះជាមុន

### អត្ថប្រយោជន៍សម្រាប់ក្រុមគ្រួសារ

ប្រសិនបើគ្រួសារមួយ/អ្នកមើលថែម្នាក់ចុះឈ្មោះជាមុននោះ ពួកគាត់អាចនឹង៖

- ត្រូវបានអញ្ជើញឲ្យចូលរួមកម្មវិធីមត្តេយ្យសាលានៅសាលាដែលនៅទីនោះពួកគាត់អាចជួបឪពុកម្តាយដទៃៗទៀត លោកគ្រូអ្នកគ្រូ និងធ្វើទស្សនកិច្ចជុំវិញសាលា។
- ស្នើសុំអ្នកបកប្រែក្នុងពេលនៃដំណើរការចុះឈ្មោះ។
- ដឹងពីប្រភពជំនួយនានា ដូចជាគ្លីនិកផ្តល់ថ្នាំបង្ការ កន្លែងញ៉ាំអាហាររដូវក្តៅ និងជាច្រើនទៀត។
- មានពេល និងការជួយគាំទ្រពីសាលា ដើម្បីចុះឈ្មោះទទួលបានអាហារ ការធ្វើដំណើរតាមរថយន្តក្រុង និងកម្មវិធីក្រៅម៉ោងសិក្សា។

### អត្ថប្រយោជន៍សម្រាប់កុមារ

ប្រសិនបើកុមារម្នាក់ត្រូវបានចុះឈ្មោះមុនខែមិថុនា៖

- ពួកគេអាចនឹងមានឱកាសដើម្បីចូលរួមក្នុងកម្មវិធីផ្ទេរការសិក្សានៅមត្តេយ្យសាលា។
- ថ្នាក់រៀនត្រៀមជាស្រេចសម្រាប់កុមារ—ពោលគឺពួកគេមានកន្លែងដាក់របស់ផ្ទាល់ខ្លួន សម្ភារៈរបស់ពួកគេត្រូវបានរៀបចំឲ្យ ពួកគេទទួលអារម្មណ៍ស្វាគមន៍ និងហាក់ដូចជាពួកគេមានចំណែកក្នុងថ្នាក់រៀននោះដែរ។
- លោកគ្រូអ្នកគ្រូត្រៀមជាស្រេចសម្រាប់កុមារ ពួកគាត់អាចនិយាយរាក់ទាក់កុមារទាំងនោះដោយហៅឈ្មោះ ស្វាគមន៍ពួកគេមកថ្នាក់រៀន និងចាប់ផ្តើមឆ្នាំសិក្សាបានភ្លាម!

### អត្ថប្រយោជន៍សម្រាប់សាលា

នៅពេលដែលក្រុមគ្រួសារចុះឈ្មោះបានទាន់ពេល៖

- សាលាដឹងថាត្រូវត្រៀមសម្រាប់កុមារនិងក្រុមគ្រួសារចំនួនប៉ុន្មាននាក់ ត្រូវជួលគ្រូបង្រៀនចំនួនប៉ុន្មាននាក់ និងថ្នាក់រៀនណាខ្លះនឹងត្រូវប្រើ។
- លោកគ្រូអ្នកគ្រូ និងបុគ្គលិកសាលាអាចជួបជាមួយកុមារ និងក្រុមគ្រួសារ មុនពេលឆ្នាំសិក្សាចាប់ផ្តើម។
- សាលាអាចជួយបំពេញតម្រូវការរបស់ក្រុមគ្រួសារចាប់ពីដើមដំបូង និងចាប់ផ្តើមភាពជាដៃគូដើម្បីជោគជ័យរបស់កុមារ។

## ការប្រឈមនានានៃការមិនបានចុះឈ្មោះជាមុន

### ការប្រឈមនានាចំពោះក្រុមគ្រួសារ

នៅពេលក្រុមគ្រួសារ/អ្នកមើលថែ បង្អែបង្អង់ចុះឈ្មោះនោះ ពួកគាត់អាចនឹង៖

- មិនទទួលបានការយកចិត្តទុកដាក់ជាលក្ខណៈបុគ្គលិកពីលោកគ្រូអ្នកគ្រូ លេខាធិការនៅសាលា ឬនាយកសាលា ដើម្បីដឹងអំពីសាលា ឬចែករំលែកព័ត៌មានអំពីកូនរបស់ពួកគាត់។
- ត្រូវរង់ចាំពាក្យស្នើសុំការផ្តល់អាហារដោយឥតគិតថ្លៃ/ដោយបញ្ចុះតម្លៃរបស់ពួកគាត់ត្រូវបានដំណើរការ។
- ត្រូវដឹកកូនៗរបស់គាត់ទៅសាលានៅដើមឆ្នាំសិក្សា ដោយរង់ចាំគេរៀបចំកាលវិភាគរថយន្តក្រុងឡើងវិញ។

### ការប្រឈមនានាចំពោះកុមារ

ប្រសិនបើកុមារម្នាក់មិនបានចុះឈ្មោះជាមុន៖

- ពួកគេអាចនឹងខកខានថ្ងៃចូលរៀនដំបូងសំខាន់ៗ។
- ថ្នាក់រៀនអាចនឹងមានសិស្សច្រើនពេកសម្រាប់រយៈពេលប៉ុន្មានសប្តាហ៍ដំបូង ដោយរង់ចាំគ្រូបន្ថែមត្រូវបានជួលមកបង្រៀន។
- ពួកគេអាចនឹងខកខានពេលអាហារ ឬការជិះរថយន្តក្រុង ក្នុងពេលប៉ុន្មានសប្តាហ៍នៃការចូលរៀនដំបូងៗនោះ ដោយរង់ចាំគេដំណើរការសំណុំឯកសារ។
- ពួកគេអាចនឹងខកខានសកម្មភាពសំខាន់ៗ ដូចជាការកសាងសហគមន៍/ការជួបដើម្បីស្គាល់គ្នា/សកម្មភាពមិត្តភាព។

### ការប្រឈមនានាចំពោះសាលា

នៅពេលក្រុមគ្រួសារមិនបានចុះឈ្មោះជាមុននោះ៖

- សាលាមិនអាចធ្វើផែនការសម្រាប់ចំនួនគ្រូបង្រៀន ការរៀបចំថ្នាក់រៀន តម្រូវការការដឹកជញ្ជូនសិស្សបានឡើយ។
- បុគ្គលិកសាលានឹងជួបភាពតានតឹង និងស្មុគស្មាញ ដោយត្រូវធ្វើការរៀបចំជាថ្មីឡើងវិញសម្រាប់ការចុះឈ្មោះយឺតយ៉ាវនោះ។
- បុគ្គលិកសាលាមិនបានជួបក្រុមគ្រួសារដើម្បីដឹងថាតើពួកគេអាចជួយផ្តល់ការគាំទ្របានល្អបំផុតដោយរបៀបណា នោះទេ។

**www.KRegNow.org**